# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រម

១៨-០១-២០០៦ -ព្រះរាជក្រម នស/រកម/០១០៦/០០៥ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ៦៥៦

## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ

៣០-០១-២០០៦ -អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពីការកំណត់កាលបរិច្ឆេទ ការរៀបចំ និងការប្រព្រឹត្តទៅនៃការធ្វើជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា ឆ្នាំ ២០០៨ ៧១៦

៣១-០១-២០០៦ -អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពីការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃក្រសួងផែនការ ៧២១

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៧៧ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧២៣

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៧៨ អនក្រ.តត ស្តីពីការជូនមេដាយសុវត្ថារា ៧២៨

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៧៩ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៣០

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៨០ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៣១

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៨១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៧៣៩

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៨២ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៧៤០

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៨៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៧៤២

៣១-០១-២០០៦ -អនុក្រឹត្យលេខ ៨៤ អនក្រ.តត ស្តីពីការដាក់ឱ្យចូលនិវត្តន៍មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ៧៤៣

### ២-សារាចរ

៣១-០១-២០០៦ -សារាចរលេខ ០១ សរ ស្តីពីការផ្សាយពាណិជ្ជកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា ៧៤៤

## III-ការិយាល័យក្រសួង

### ទីស្តីការរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម

១៣-០១-២០០៦ -លិខិតលេខ ១៩៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន អេស ធី អិច ត្រេឌ ៧៤៦

១៣-០១-២០០៦ -លិខិតលេខ ២០២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អាណូដាត អ៊ីវ្រូតិច** ៧៤៨

១៣-០១-២០០៦ -លិខិតលេខ ២០៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ហងឡ្យហើរ** ៧៥០

១៦-០១-២០០៦ -លិខិតលេខ ២០៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **តូប៉ាស ខូ អិលធីឌី** ៧៥២

១៦-០១-២០០៦ -លិខិតលេខ ២០៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់
ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ុនយ៉ុនហ្វាត (ខេមបូឌា)**
**ត្រេនស្ពតថេសិន អេន ត្រេឌីង** ៧៥៤

១៦-០១-២០០៦ -លិខិតលេខ ២១០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **អេស៊ា មេនូហ្វេកឈើរីង ខូ អិលធីឌី** ៧៥៦

១៦-០១-២០០៦ -លិខិតលេខ ២១៣ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី ហ្វាង គូ ហ្វីន** ៧៥៨

១៦-០១-២០០៦ -លិខិតលេខ ២១៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី.ជេ.ស៊ី** ៧៦០

១៦-០១-២០០៦ -លិខិតលេខ ២១៥ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ស៊ី អិម អាយ ស៊ី គ្រុប** ៧៦២

១៧-០១-២០០៦ -លិខិតលេខ ២១៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជា
នីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន **ធី.អេច ខនស្ត្រាក់សិន** ៧៦៤

# ព្រះរាជក្រម

នស/រកម/០១០៦/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដែលធ្វើនៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី នាថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

នស/រកម.០១០៦.០២៣ **ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ស៊ុន ចាន់ថុល**

លេខ: ៣៦ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០០៦
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សារ៉ាវី តាន់**

# ពិធីសារទី ៩

# ស្តីពី

# ទំនិញគ្រោះថ្នាក់

# DANGEROUSE GOODS

Protocol9.doc

# ពិធីសារទី ៩
# ទំនិញគ្រោះថ្នាក់

# PROTOCOL 9
# DANGEROUS GOODS

រដ្ឋាភិបាលរបស់ប្រទេស ព្រុយណេ ដារូសសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូនេស៊ី, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ម៉ាឡេស៊ី, សហភាពមីយ៉ានម៉ា, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៍ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាប្រទេសសមាជិក នៃសមាគមន៍ប្រជាជាតិអាស៊ី ភាគអគ្នេយ៍ ( ហៅកាត់ថាភាគីចុះកិច្ចសន្យា ) ។

**រំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខានៅថ្ងៃទី ១៦ ធ្នូ ១៩៩៨ នៅទីក្រុងហាណូយប្រទេសវៀតណាម ( ហៅកាត់ថាកិច្ចព្រមព្រៀង ) ។

**ទទួលស្គាល់ថា** មាត្រា ២០ និង ២៥ ដែលចែងពីការសំរេចលើការអនុវត្តន៍ពិធីសារផ្សេងៗ នឹងបង្កើតឡើងទៅជាផ្នែករួមបញ្ចូលគ្នានៃកិច្ចព្រមព្រៀង ។

**នៅពេលនេះ, ព្រោះហេតុនេះ, ភាគីចុះកិច្ចសន្យាទាំងឡាយបានឯកភាពដូចតទៅ :**

## មាត្រាទី ១
## និយមន័យ

**សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

ក- "ទំនិញគ្រោះថ្នាក់" "មធ្យោបាយដឹកជញ្ជូន" និង "ការដឹកជញ្ជូនឆ្លងកាត់" ត្រូវមាននិយមន័យដូចដែលបានកំណត់អោយក្នុងកិច្ចព្រមព្រៀង ។

ខ- " និយ័តកម្មជាគំរូរបស់អង្គការសហប្រជាជាតិ " មានន័យថា ជាអនុសាសន៍ អង្គការសហប្រជាជាតិ ស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ ឬជានិយ័តកម្មគំរូម៉ូដែល ។

គ- " ADR " មានន័យថា កិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធដល់ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ជាអន្តរជាតិតាមផ្លូវថ្នល់

ឃ- " ការកែសំរួលឡើងវិញ ADR " មានន័យថា កែសំរួលសេចក្តីបកស្រាយ នៃកិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវថ្នល់ ដែលអនុវត្តពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០១ ។

ង- " ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ " មានអត្ថន័យដូចដែលបានកំណត់ក្នុងពិធីសារទី ៣ ស្តីពីប្រភេទ និងបរិមាណយានយន្តតាមផ្លូវគោក អនុលោមទៅតាមកិច្ចព្រមព្រៀង ។

## មាត្រា ទី ២
## ទំហំនៃការអនុវត្តន៍

អនុលោមទៅតាមប្រការទី ២០ នៃកិច្ចព្រមព្រៀង, ភាគីចុះកិច្ចសន្យានៅទីនេះយល់ព្រមធ្វើតាមទៅលើប្រការ ដែលមានចែងក្នុងពិធីសារនេះ លើការធ្វើចលនាទំនិញគ្រោះថ្នាក់ទាំងឡាយ ក្នុងការដឹកជញ្ជូនឆ្លងកាត់ តាមផ្លូវថ្នល់ ( ឬ ផ្លូវហាយវេយរវាងរដ្ឋ ) ដែលបានកំណត់ថាជាផ្លូវដឹកជញ្ជូនឆ្លងកាត់ ដូចមានបញ្ជាក់ក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀង ។

## មាត្រា ទី ៣
## ការចាត់ថ្នាក់នូវទំនិញគ្រោះថ្នាក់

ទំនិញគ្រោះថ្នាក់ទាំងឡាយ ត្រូវបានគេបែងចែកទៅតាមចំណាត់ថ្នាក់ ឬផ្នែកដូចខាងក្រោម :

ចំណាត់ថ្នាក់ទី ១ : គ្រឿងផ្ទុះ ( Explosives )

ចំណាត់ថ្នាក់ទី ២ : ផ្នែកទី ២-១ : ឧស្ម័នអាចឆេះ ( Flammable Gases )

ផ្នែកទី ២-២ : ឧស្ម័នដែលមិនអាចឆេះ-មិនមានជាតិពុល (Non-flammable, Non-toxic gases )

ផ្នែកទី ២-៣ : ឧស្ម័នពុល ( Toxic gases)

ចំណាត់ថ្នាក់ទី ៣ : វត្ថុរាវអាចឆេះ និងវត្ថុរាវដែលងាយនឹងផ្ទុះ ( Flammable Liquids and desensitized explosives )

ចំណាត់ថ្នាក់ទី ៤ : ផ្នែកទី ៤-១ : វត្ថុរឹងអាចឆេះ, សារធាតុវិទ្យុសកម្មនិងវត្ថុធាតុរឹងដែលងាយបង្កឱ្យផ្ទុះ ( Flammable Solids self-reactive substances and solid desensitized explosive)

ផ្នែកទី ៤-២ : សារធាតុដែលអាចមានចំហេះដោយឯកឯង ( Substances liable to spontaneous combustion )

ផ្នែកទី ៤-៣ : សារធាតុទាំងឡាយដែលមានប្រតិកម្មជាមួយទឹកអាចបញ្ចេញឧស្ម័នឆេះ ( Substances which in contact with water emit flammable gases )

ចំណាត់ថ្នាក់ទី ៥ : ផ្នែកទី ៥-១ : សារធាតុឱ្យអុកស៊ីត ( Oxidizing substances )

ផ្នែកទី ៥-២ : សរីរាង្គពីរ៉ុកស៊ីដ ( Organic peroxide )

ចំណាត់ថ្នាក់ទី ៦ : ផ្នែកទី ៦-១ : សារធាតុពុល ( Toxic substances )

ផ្នែកទី ៦-២ : សារធាតុឆ្លង ( Infectious substances )

ចំណាត់ថ្នាក់ទី ៧ : គ្រឿងវិទ្យុសកម្ម ( Radioactive material )

ចំណាត់ថ្នាក់ទី ៨ : សារធាតុដែលស៊ី ឬ កាត់ ( អាស៊ីត) ( Corrosive substances )

ចំណាត់ថ្នាក់ទី ៩ : សារធាតុ និងអង្គធាតុគ្រោះថ្នាក់ផ្សេងទៀត ( Miscellaneous dangerous substances and articles )

ការចាត់ថ្នាក់ទំនិញគ្រោះថ្នាក់ ទៅតាមប្រភេទចំណាត់ថ្នាក់ និងផ្នែកដូចខាងលើ ត្រូវធ្វើឡើងស្របទៅតាមផ្នែកទី ២ នៃគំរូម៉ូដែលបទប្បញ្ញត្តិរបស់អង្គការសហប្រជាជាតិ ឬក៏កំណែសំរួលជាថ្មីនៃ ADR ។

## មាត្រា ៤

## ការអនុម័ត និយ័តកម្មជាគំរូរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR

សំរាប់គោលបំណង នៃកិច្ចប្រតិបត្តិពិធីសារនេះ ភាគីចុះកិច្ចសន្យាទាំងឡាយនៅទីនេះទទួលយល់ព្រមចាប់ផ្តើមប្រើប្រាស់និយ័តកម្មទាំងឡាយដែលជាគំរូម៉ូដែលរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR ដែលជាពិសេសទាក់ទងទៅនិងលក្ខណៈផ្សេងៗដូចខាងក្រោម :

១- ការលំអិតចំណាត់ថ្នាក់ និងផ្នែកទាំងឡាយនៃទំនិញគ្រោះថ្នាក់

២- ការវេចខ្ចប់ និងការដាក់ផ្លាកសញ្ញាសំគាល់ទំនិញគ្រោះថ្នាក់

៣- ការលាបពណ៌យានយន្ត និងវិធីសាស្រ្តក្នុងការវេចខ្ចប់

៤- ឯកសារដឹកជញ្ជូន និងសេចក្តីប្រកាស

៥- ការហ្វឹកហាត់

៦- ការព្រមានប្រឆាំងទល់នឹងភ្លើងឆេះ និង/ ឬក៏ការផ្ទុកទាំងឡាយ ។

## មាត្រា ៥

## ការអនុញ្ញាត

១- ការដឹកជញ្ជូនឆ្លងកាត់នូវទំនិញទាំងឡាយណា ដែលមានចូលក្នុងប្រភេទលក្ខណៈណាមួយ ឬក៏ចំណាត់ថ្នាក់ដូចបានកំណត់ក្នុងមាត្រា ៣ និង បទប្បញ្ញត្តិនៃមាត្រា ៤ នៅក្នុងទីនេះ មិនត្រូវបានគេអនុវត្តដោយអ្នកធ្វើប្រតិបត្តិការដឹកជញ្ជូនឆ្លងកាត់ណាមួយឡើយ លើកលែងតែមានការអនុញ្ញាតណាមួយ សំរាប់គោលបំណងបែបនេះ ត្រូវបានគេចេញអោយដោយអាជ្ញាធរពាក់ព័ន្ធទាំងឡាយ នៃភាគីចុះកិច្ចសន្យា ដែលការដឹកជញ្ជូនឆ្លងកាត់ ធ្វើឡើងកាត់តាមដែនដី នៃភាគីនោះ ។

២- ពាក្យសុំសំរាប់ការអនុញ្ញាត ដូចបានអធិប្បាយខាងលើ ត្រូវបានគេធ្វើឡើង ជូនទៅគណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ នៃភាគីចុះកិច្ចសន្យាដែលពាក់ព័ន្ធ ។

៣- នៅពេលដែលពាក្យសុំមួយ ធ្វើឡើងទៅគណៈកម្មការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ នៃភាគីចុះកិច្ចសន្យាដែលពាក់ព័ន្ធ គណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់នោះ ត្រូវទាក់ទងជាមួយគណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ នៃភាគីចុះកិច្ចសន្យាម្ខាងទៀត ដែលការដឹកជញ្ជូនឆ្លងកាត់ទាំងឡាយ ធ្វើឡើងកាត់តាមដែនដី នៃភាគីនោះ ។

៤- ការអនុញ្ញាតណាមួយប្រសិនបើមិនបានសរសេរជាភាសាអង់គ្លេស ត្រូវតែភ្ជាប់ដោយការបកប្រែបញ្ជាក់ជាភាសាអង់គ្លេស ដែលចេញអោយដោយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ។

៥- សំរាប់ជៀសវាងនៃការសង្ស័យ គណៈកម្មាការជាតិសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ មិនត្រូវបានគេចាត់ជាអាជ្ញាធរមានសិទ្ធិអនុម័តក្នុងការអនុញ្ញាត ដូចបានរៀបរាប់អធិប្បាយ ប៉ុន្តែគ្រាន់តែសំរួល និងផ្តល់ការទំនាក់ទំនងរវាងអ្នកស្នើសុំ និង អាជ្ញាធរមានសិទ្ធិផ្តល់ការយល់ព្រម-អនុម័ត ដែលពាក់ព័ន្ធ ។

## មាត្រា ៦

## ការរៀបចំស្ថាប័ននាំឲ្យ

១- កិច្ចប្រជុំនានារបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ានត្រូវតែជាអ្នកទទួលខុសត្រូវសំរាប់ការត្រួតពិនិត្យ តាមដានការពិនិត្យមើលឡើងវិញ សំរបសំរួល និង ត្រួតត្រាមើល នូវទិដ្ឋភាពទាំងអស់ ដែលពាក់ព័ន្ធទៅដល់ការអនុវត្តន៍ដោយមានប្រសិទ្ធិភាព នូវពិធីសារនេះ ។

២- កិច្ចប្រជុំរបស់មន្ត្រីដឹកជញ្ជូនជាន់ខ្ពស់អាស៊ាន ត្រូវដាក់ស្នើតាមរយៈលេខាធិការដ្ឋានអាស៊ាន នូវរបាយការណ៍ជាទៀងទាត់ទាំងឡាយ ស្តីពីភាពជឿនលឿន នៃការប្រតិបត្តិរបស់ពិធីសារនេះ ទៅក្រុមប្រឹក្សាភិបាលសំរបសំរួលការដឹកជញ្ជូនឆ្លងកាត់ សំរាប់សកម្មភាពនានាបន្ថែមទៀត ។

៣- លេខាធិការដ្ឋានអាស៊ានត្រូវផ្តល់នូវការទ្រទ្រង់ និងជំនួយបច្ចេកទេសជាចាំបាច់ទៅដល់កិច្ចប្រជុំមន្ត្រីដឹកជញ្ជូនជាន់ខ្ពស់ទាំងឡាយរបស់អាស៊ានក្នុងមុខការ និងការទទួលខុសត្រូវរបស់គេ ទៅតាមពិធីសារនេះ ។

## មាត្រា ៧
## អវសានបញ្ញត្តិ

១- ពិធីសារនេះ នឹងត្រូវតំកល់ទុកនៅអគ្គលេខាធិការដ្ឋានអាស៊ាន ដែលជាអ្នកផ្សព្វផ្សាយយ៉ាងរហ័ស នូវច្បាប់ចំលងមួយដែលមានបញ្ជាក់ដូចគ្នានេះ ទៅភាគីចុះកិច្ចសន្យានីមួយៗ ។

២- ពិធីសារនេះ គឺជាការបង្គ្រប់បន្ថែម ពីលើកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់ដែលបានចុះហត្ថលេខានៅថ្ងៃទី១៦ ធ្នូ ១៩៩៨ នៅទីក្រុងហាណូយប្រទេសវៀតណាម និងក៏ដូចជារាងភាគីជាប់កិច្ចសន្យាទាំងឡាយចំពោះពិធីសារនេះ ។ កិច្ចព្រមព្រៀងនិងពិធីសារនេះត្រូវបានគេបញ្ចូលសព្វគ្រប់និងបកស្រាយរួមជាមួយគ្នាដូចជាលិខិតតុបករណ៍តែមួយ ។

៣- ពិធីសារនេះគឺជាកម្មវត្ថុក្នុងការធ្វើសច្ចាប័ន ឬ ការយល់ព្រមដោយភាគីចុះកិច្ចសន្យា ។ លិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមចូលត្រូវគេតំកល់ទុកទៅជាមួយអគ្គលេខាធិការអាស៊ាន ដែលជាអ្នកផ្តល់ពត៌មានយ៉ាងរហ័សទៅភាគីចុះកិច្ចសន្យានីមួយៗ នូវការតំកល់ទុកនេះ ។

៤- ពិធីសារនេះនឹងត្រូវចូលជាធរមាន ក្នុងពេលដែលការតំកល់ទុកនូវលិខិតតុបករណ៍ នៃការធ្វើសច្ចាប័ន ឬ ការយល់ព្រមធ្វើឡើងពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ នៅជាមួយអគ្គលេខាធិការអាស៊ាន ។

៥- ការធ្វើវិសោធនកម្មណាមួយ ទៅលើប្រការទាំងឡាយដែលមានចែងក្នុងពិធីសារនេះ និងឧបសម្ព័ន្ធទាំងឡាយរបស់វាសំរេចទៅបានតាមរយៈការព្រមព្រៀងគ្នាពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

៦- សេចក្តីយោងក្នុងពិធីសារនេះ ទៅតាមនិយ័តកម្មជាគំរូម៉ូរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR និងប្រែក្លាយសេចក្តីបកស្រាយអធិប្បាយ ទៅតាមសេចក្តីបកស្រាយអធិប្បាយ ដែលមានអាទិភាពស្រាប់ នៃ

លិខិតតុបករណ៍ទាំងនេះចាប់ពីថ្ងៃចុះហត្ថលេខាលើពិធីសារនេះ ។ ការអនុវត្តន៍ នៃការបកស្រាយ ឬ ការកែប្រែនៅថ្ងៃខាងមុខ ទៅលើនិយ័តកម្មជាគំរូម៉ូដែលរបស់អង្គការសហប្រជាជាតិ ADR និងការកែសំរួល ADR ត្រូវតែមានការឯកភាពពីគ្រប់ភាគីចុះកិច្ចសន្យាទាំងអស់ ។

ជាសក្ខីភាពនៅទីនេះ ហត្ថលេខីខាងក្រោម បានទទួលសិទ្ធិប្រទានយ៉ាងត្រឹមត្រូវ ដើម្បីចុះហត្ថលេខាពីរដ្ឋាភិបាលរបស់ពួកគេទាំងឡាយរៀង១ខ្លួន បានចុះហត្ថលេខាលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដើម្បីអនុវត្តកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ។

ធ្វើនៅទីក្រុង ហ្សាការតា នៅថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ជាភាសាអង់គ្លេសតែមួយច្បាប់គត់ ។

**តំណាងរដ្ឋាភិបាលប្រ៊ុយណេដារូសាឡាម**

PENIN DATO HAJI ZAKARIA SULAIMAN
**រដ្ឋមន្ត្រី គមនាគមន៍**

**តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រកម្ពុជា**

KHY TAINGLIM
**រដ្ឋមន្ត្រីសាធារណការ និងដឹកជញ្ជូន**

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋឥណ្ឌូណេស៊ី**

AGUM GUMELAR
**រដ្ឋមន្ត្រី គមនាគមន៍**

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ**

BOUATHONG VONGLOKHAM
**រដ្ឋមន្ត្រី គមនាគមន៍ ដឹកជញ្ជូន ប្រៃសណីយ៍ និងសំណង់**

**តំណាងរដ្ឋាភិបាល ម៉ាឡេស៊ី**

DATO' SERI DR. LING LIONG SIK
រដ្ឋមន្ត្រី ដឹកជញ្ជូន

**តំណាងរដ្ឋាភិបាល សហភាពមីយ៉ាន់ម៉ា**

MAJ GEN HLA MYINT SWE
រដ្ឋមន្ត្រី ដឹកជញ្ជូន

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋហ្វីលីពីន**

ARTURO T.VALDEZ
រដ្ឋលេខាធិការ ដឹកជញ្ជូន និងគមនាគមន៍

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋសិង្ហបុរី**

YEO CHEOW TONG
រដ្ឋមន្ត្រី គមនាគមន៍ និងបច្ចេកវិទ្យាព័ត៌មាន

**តំណាងរដ្ឋាភិបាល ព្រះរាជាណាចក្រថៃឡង់ដ៍**

NIKORN CHAMNONG
អនុរដ្ឋមន្ត្រី ដឹកជញ្ជូន និងគមនាគមន៍

**តំណាងរដ្ឋាភិបាល សាធារណរដ្ឋសង្គមនិយមវៀតណាម**

DR.TRAN DOAN THO

អនុរដ្ឋមន្ត្រី ដឹកជញ្ជូន

# PROTOCOL 9

# DANGEROUS GOODS

The Governments of Brunei Darussalam, the Kingdom of Cambodia, the Republic of Indonesia, the Lao People's Democratic Republic, Malaysia, the Union of Myanmar, the Republic of the Philippines, the Republic of Singapore, the Kingdom of Thailand and the Socialist Republic of Viet Nam, Member States of the Association of Southeast Asian Nations (hereinafter referred to as "Contracting Parties");

**RECALLING** the ASEAN Framework Agreement on the Facilitation of Goods in Transit signed on 16 December 1998 in Hanoi, Viet Nam (hereinafter referred to as "the Agreement");

**RECOGNISING** that Articles 20 and 25 thereof provide for the conclusion of implementing Protocols which shall form integral parts of the Agreement;

**NOW, WHEREFORE,** the Contracting Parties have agreed as follows:

## Article 1
## Definition

For the purposes of this Protocol,

(a) "Dangerous Goods", "Means of Transport" and "Transit Transport" shall have the meanings assigned to them in the Agreement.

CERTIFIED COPY
SECRETARY GENERAL OF ASEAN

(b) "UN Model Regulations" means the United Nations Recommendations on the Transport of Dangerous Goods / Model Regulations.

(c) "ADR" means the European Agreement Concerning the International Carriage of Dangerous Goods by Road.

(d) "Restructured ADR" means the restructured version of the European Agreement Concerning the International Carriage of Dangerous Goods by Road, applicable from 1 July 2001.

(e) "Transit Transport Operators" shall have the meaning assigned to it in Protocol 3-Types and Quantity of Road Vehicles pursuant to the Agreement.

## Article 2
## Scope of Application

Pursuant to Article 20 of the Agreement, the Contracting Parties hereby agree to apply the provisions of this Protocol to the movement of dangerous goods in transit transport on designated road (or inter-state highway) transit transport routes as specified in Protocol 1 of the Agreement.

## Article 3
## Classification

Dangerous goods shall be divided into the following classes/divisions:

| | | |
|---|---|---|
| Class 1: | Explosives | |
| Class 2: | Division 2.1 : | Flammable gases |
| | Division 2.2 : | Non-flammable, non-toxic gases |
| | Division 2.3 : | Toxic gases |

CERTIFIED COPY SECRETARIAT

| | | |
|---|---|---|
| Class 3: | Flammable liquids and liquid desensitized explosives | |
| Class 4: | Division 4.1 : | Flammable solids, self-reactive substances and solid desensitized explosives |
| | Division 4.2 : | Substances liable to spontaneous combustion |
| | Division 4.3 : | Substances which in contact with water emit flammable gases |
| Class 5: | Division 5.1 : | Oxidizing substances |
| | Division 5.2 : | Organic peroxides |
| Class 6: | Division 6.1 : | Toxic substances |
| | Division 6.2 : | Infectious substances |
| Class 7: | Radioactive material | |
| Class 8: | Corrosive substances | |
| Class 9: | Miscellaneous substances and articles | |

Assignment of dangerous goods to the above classes/divisions shall be made in accordance with Part 2 of the UN Model Regulations or of the Restructured ADR.

### Article 4

### Adoption of the UN Model Regulations, ADR and the Restructured ADR

For the purposes of the implementation of this Protocol, the Contracting Parties hereby agree to adopt the provisions of the UN Model Regulations, ADR and the Restructured ADR, in particular relating to the following:

CERTIFIED COPY SECRETARIAT OF ASEAN

(i) detailed classes and divisions of dangerous goods;

(ii) packaging and labeling of dangerous goods;

(iii) vehicle marking and method of packaging;

(iv) transport document and declaration;

(v) training; and

(vi) precautions against Fire and/or Explosions.

Article 5

**Permit**

1. Transit transport of any goods which falls within any category or classification as stated in Article 3 and the provisions of Article 4 herein shall not be carried out by any transit transport operators unless a permit for such purpose has been issued by the relevant authorities of the Contracting Parties across whose territory the transit transport passes.

2. Application for the said permit shall be made to the National Transit Transport Coordinating Committee of the relevant Contracting Party.

3. When an application is made to the National Transit Transport Coordinating Committee of the relevant Contracting Party, that National Transit Transport Coordinating Committee shall liaise with the National Transit Transport Coordinating Committee of the Contracting Party across whose territory the transit transport passes.

4. Any permit if not drawn up in English shall be accompanied by a certified translation in English issued by the relevant competent authority.

CERTIFIED COPY
SECRETARY GENERAL OF ASEAN
asean

5. For the avoidance of doubt, the National Transit Transport Coordinating Committees shall not be deemed to be the approving authority of the said permit but merely to facilitate and provide liaison between the applicant and the relevant approving authority.

Article 6

**Institutional Arrangements**

1. The ASEAN Senior Transport Officials Meeting shall be the responsible body for the monitoring, review, coordination and supervision of all aspects relating to the effective implementation of this Protocol.

2. The ASEAN Senior Transport Officials Meeting shall submit, through the ASEAN Secretariat, regular reports of the progress of implementation of this Protocol to the Transit Transport Coordinating Board, for further action.

3. The ASEAN Secretariat shall provide the necessary technical support and assistance to the ASEAN Senior Transport Officials Meeting in its functions and responsibilities under this Protocol.

Article 7

**Final Provisions**

1. This Protocol shall be deposited with the Secretary-General of ASEAN who shall promptly furnish a certified copy thereof to each Contracting Party.

CERTIFIED COPY SECRETARY GENERAL OF ASEAN asean

2. This Protocol shall supplement and form an integral part of the ASEAN Framework Agreement on the Facilitation of Goods in Transit signed on 16 December 1998 in Hanoi, Viet Nam and, as between the Contracting Parties to this Protocol, the Agreement and this Protocol shall be ready and interpreted together as one single instrument.

3. This Protocol is subject to ratification or acceptance by the Contracting Parties. The Instrument of Ratification or Acceptance shall be deposited with the Secretary-General of ASEAN who shall promptly inform each Contracting Party of such deposit.

4. This Protocol shall enter into force upon the deposit of Instruments of Ratification or Acceptance by all Contracting Parties with the Secretary-General of ASEAN.

5. Any amendment to the Provisions of this Protocol shall be effected by consent of all the Contracting Parties.

6. References in this Protocol to the UN Model Regulations, ADR and the Restructured ADR shall be to the versions of these instruments in existence as of the date of signature of this Protocol. The applicability of future revisions or amendments to the UN Model Regulations, ADR and the Restructured ADR shall be effected by consent of all the Contracting Parties.

**IN WITNESS WHEREOF**, the undersigned, being duly authorized to sign by their respective Governments, have signed Protocol 9 - Dangerous Goods to implement the ASEAN Framework Agreement on the Facilitation of Goods in Transit.

CERTIFIED COPY SECRETARY GENERAL OF ASEAN

DONE at Jakarta, Indonesia on the 20th day of September 2002, in a single copy in the English language.

For Government of Brunei Darussalam

..................

**PEHIN DATO ZAKARIA SULAIMAN**
Minister of Communications

For the Government of Kingdom of Cambodia

..................

**KHY TAINGLIM**
Minister of Public Works and Transport

For the Government of the Republic of Indonesia

..................

**AGUM GUMELAR**
Minister of Communications

For the Government of the Lao People's Democratic Republic

..................

**BOUATHONG VONGLOKHAM**
Minister of Communication, Transport, Post and Construction

CERTIFIED COPY
SECRETARY GENERAL OF ASEAN

**For the Government of Malaysia**

…………………………
**DATO' SERI DR. LING LIONG SIK**
Minister of Transport

**For the Government of the Union of Myanmar**

…………………………
**MAJOR GENERAL HLA MYINT SWE**
Minister of Transport

**For the Government of the Republic of the Philippines**

…………………………
**ARTURO T. VALDEZ**
Undersecretary of Transportation

**For the Government of the Republic of Singapore**

…………………………
**YEO CHEOW TONG**
Minister for Transport

CERTIFIED COPY
SECRETARY GENERAL OF ASEAN
asean

**For the Government of Kingdom of Thailand**

....................

**NIKORN CHAMNONG**
Deputy Minister of Transport and Communications

**For the Government of the Socialist Republic of Viet Nam**

....................

**DR. TRAN DOAN THO**
Vice Minister of Transport

CERTIFIED COPY
SECRETARY GENERAL OF ASEAN
asean

# កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន
# ស្តីពី
# ការសម្រួលទំនិញឆ្លងកាត់

# ASEAN FRAMEWORK AGREEMENT ON THE FACILITATION OF GOOD IN TRANSIT

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

# កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរួលទំនិញឆ្លងកាត់

❖❖❖❖❖ ❖❖❖❖❖

## បុព្វកថា

សមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( ខាងក្រោមនេះហៅកាត់ថា ភាគីជាប់កិច្ចសន្យា ) :

**ដោយគ្រូវបណ្តុះគំនិត** ដើម្បីថែរក្សា អភិវឌ្ឍន៍បន្ថែមទៀត និងពង្រឹងឡើងនូវទំនាក់ទំនងជាមិត្តភាព និងសហប្រត្តិបត្តិការរវាងប្រទេសពួកគេទាំងអស់ ។

**រំលឹកឡើងវិញបន្ថែម** នូវការសន្យារបស់គេ ក្នុងការជំរុញចលនាទំនិញរវាងគ្នា និងក្នុងរង្វង់ភាគីជាប់កិច្ចសន្យាអោយរីកចំរើនឡើងឥតអាក់ យ៉ាងរហ័ស និងមានប្រសិទ្ធិភាព ។

**រំលឹកឡើងវិញ** ការសំរេចចិត្តនៃសន្និសិទ្ធកំពូលក្រៅផ្លូវការអាស៊ានលើកទី១ ធ្វើនៅថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ១៩៩៦ នៅយ៉ាការតា និងសន្និសិទ្ធកំពូលក្រៅផ្លូវការអាស៊ានលើកទី ២ ធ្វើនៅថ្ងៃទី ១៥ ធ្នូ ឆ្នាំ ១៩៩៧ នៅ កូឡាឡាំពួរ ដើម្បីសំរួលកិច្ចសហប្រតិបត្តិការក្នុងតំបន់ នៃការដឹកជញ្ជូនទំនិញឆ្លងកាត់ និងសិក្សាអោយបានឆាប់រហ័ស នូវវិធានការចាំបាច់ដើម្បីសំរួលក្នុងការដឹកជញ្ជូនទំនិញ ទាំងឆ្លងកាត់ និងរវាងរដ្ឋ ដែលរាប់ទាំងការដឹកទំនិញតាមផ្លូវគោក តាមនាវាសមុទ្រ និងការតភ្ជាប់ផ្លូវអាកាស នៃប្រទេសនិមួយៗ ។

**ការកត់សំគាល់** មាត្រា ៥ នៃកិច្ចប្រមព្រៀងជាទូទៅ ស្តីពីពន្ធគយ និងពាណិជ្ជកម្ម ( GATT1994 ) " ស្តីពីការដឹកជញ្ជូនឆ្លងកាត់ដោយសេរី " និងអនុសញ្ញាអន្តរជាតិផ្សេងៗទៀត ដែលជាប់ពាក់ព័ន្ធ និងទំនិញឆ្លងកាត់ ។

**យល់ព្រមថា** កិច្ចព្រមព្រៀងជាមូលដ្ឋានរបស់អាស៊ាន ស្តីពីការសំរួលក្នុងការដឹកជញ្ជូនទំនិញឆ្លងកាត់ ( តទៅហៅកាត់ថា " កិច្ចព្រមព្រៀងនេះ " ) ផ្តល់អោយនូវកិច្ចរៀបចំដ៏មានប្រសិទ្ធភាព សំរាប់សំរួលដល់ចរាចររវាងរដ្ឋ និងការដឹកជញ្ជូនឆ្លងកាត់ក្នុងរង្វង់ប្រទេសអាស៊ាន ។

**ខ្វល់ខ្វាយ** ក្នុងការលើកទឹកចិត្ត និងសំរួលដល់ចរាចររវាងរដ្ឋ និងការដឹកជញ្ជូនឆ្លងកាត់ក្នុងរង្វង់ភាគីជាប់កិច្ចសន្យា

**បានព្រមព្រៀងដូចខាងក្រោមនេះ** :

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ១
## គោលបំណង

**គោលបំណងនៃកិច្ចព្រមព្រៀងនេះគឺ :**

ក- ដើម្បីសំរួលដល់ការដឹកទំនិញឆ្លងកាត់ ក្នុងការទ្រទ្រង់កិច្ចប្រតិបត្តិនូវតំបន់ពាណិជ្ជកម្មសេរីអាស៊ាន និងដើម្បីធ្វើសមាហរណកម្ម សេដ្ឋកិច្ចក្នុងតំបន់ បន្ថែមទៀត ។

ខ- ដើម្បីសំរួលអោយសាមញ្ញ និងធ្វើអោយចុះសំរុងគ្នានៃការដឹកជញ្ជូន ការធ្វើពាណិជ្ជកម្ម និងបទប្បញ្ញត្តិគយ និងតំរូវការទាំងឡាយ សំរាប់គោលបំណង នៃការសំរួលទំនិញឆ្លងកាត់. និង

គ- ដើម្បីបង្កើតឡើង នូវប្រព័ន្ធនៃការដឹកជញ្ជូនឆ្លងកាត់មួយដែលប្រកបដោយសមត្ថភាព.ប្រសិទ្ធិភាព. សមាហរណកម្ម និង ចុះសំរុងគ្នា នៅក្នុងអាស៊ាន ។

## មាត្រាទី ២
## គោលការណ៍

ភាគីចុះកិច្ចសន្យា នឹងត្រូវបានណែនាំដោយគោលការណ៍ទាំងឡាយដូចតទៅ ក្នុងក្របខ័ណ្ឌនៃកិច្ចព្រមព្រៀងនេះ :

ក- <u>ប្រព្រឹត្តិកម្មជាតិនៃការអនុគ្រោះបំផុត</u>: ភាគីជាប់កិច្ចសន្យា ត្រូវតែយល់ប្រមអនុញ្ញាតអោយធ្វើការដឹកជញ្ជូនឆ្លងកាត់ ទៅ ឬមកពីប្រទេសភាគីជាប់កិច្ចសន្យាដទៃខ្លះទៀត តាមប្រព្រឹត្តិកម្មមិនតិចជាង ប្រព្រឹត្តិកម្មដែលបានយល់ព្រម ក្នុងការ ដឹកជញ្ជូនឆ្លងកាត់ ទៅ ឬ មកពីប្រទេសដទៃណាមួយផ្សេងទៀត ។

ខ- <u>ប្រព្រឹត្តិកម្មជាតិ</u> : ភាគីចុះកិច្ចសន្យា ត្រូវតែយល់ព្រម លើផលិតផលទាំងឡាយ ដែលត្រូវដឹកជញ្ជូនឆ្លងកាត់ដោយកាត់តាមទឹកដីនៃភាគីចុះកិច្ចសន្យាដទៃណាមួយ នូវប្រព្រឹត្តិកម្ម មិនតិចជាងការអនុគ្រោះ ដែលយល់ព្រមទៅលើផលផិតផលដូចគ្នានេះ ដែលគេបានធ្វើការដឹកជញ្ជូន មកពីទីកន្លែងដើមរបស់គេ ទៅកាន់គោលដៅចុងបញ្ចប់របស់គេ ដោយមិនធ្វើ ដំណើរកាត់តាមទឹកដីនៃភាគីធ្វើកិច្ចសន្យាដទៃទៀត ។

គ- <u>និរន្តរភាព</u> : ភាគីធ្វើកិច្ចសន្យាត្រូវធានា ដល់ការអនុវត្តន៍អោយមាននិរន្តភាព នូវច្បាប់និងបទប្បញ្ញតិដែលជាប់ពាក់ព័ន្ធ និតិវិធី និងការណែនាំខាងរដ្ឋបាលគ្រប់គ្រង និងវិធានដទៃទៀត ជាមួយនិងភាគីធ្វើកិច្ចសន្យានិមួយៗ ។

ឃ- ភាពងាយស្រួល : ភាគីចុះកិច្ចសន្យា ត្រូវតែខំប្រឹងខ្នះខ្នែងធានា លើការធ្វើអោយមានភាពងាយស្រួលមិនស្មុគ្រស្មាញ នូវរាល់និតិវិធី នៃការដឹកជញ្ជូនឆ្លងកាត់ និងតំរូវការនានាក្នុងអាស៊ាន ។

ង- តំលាភាព : ភាគីចុះកិច្ចសន្យា ត្រូវតែធ្វើអោយច្បាប់ បទប្បញ្ញត្តិ និតិវិធី និងការជូនដំណឹងខាងរដ្ឋបាល (គ្រប់គ្រង) ទាំងអស់ដែលមានការទាក់ទងទៅនឹងអាជ្ញាធរដែលពាក់ព័ន្ធ អាចធ្វើទៅបានជាសាធារណៈក្នុងលក្ខណៈឆាប់រហ័ស - តំលាភាព និងងាយស្រួលរកបាន - ងាយស្រួលធ្វើតាម ។

ច- អំណោយផលល្អ : ភាគីចុះកិច្ចសន្យា ត្រូវតែធានាថា មានការគ្រប់គ្រងរដ្ឋបាល ដ៏មានអំណោយផល (អនុគ្រោះ) និងស័ក្តិសិទ្ធិ នូវការដឹកជញ្ជូនឆ្លងកាត់ ដើម្បីសំរួលចលនាទំនិញឆ្លងកាត់ ។

ឆ- សុំអោយវិនិច្ឆ័យសាជាថ្មី : ភាគីចុះកិច្ចសន្យា ត្រូវតែធានាថា មានយន្តការមួយដ៏សក្តិសិទ្ធិសំរាប់ពិនិត្យមើលឡើងវិញ នូវសេចក្តីសំរេចនានា ដោយអាជ្ញាធរដែលមានការពាក់ពន្ធ័នៃភាគីចុះកិច្ចសន្យា គឺធ្វើអោយងាយរកបាន និងងាយចូលសម្ព័ន្ធទាក់ទង សំរាប់អ្នកប្រើប្រាស់ និងអ្នកផ្គត់ផ្គង់ ការដឹកជញ្ជូនឆ្លងកាត់ នៅក្នុងអាស៊ាន ។

ជ- កិច្ចជួយឧបត្ថមគ្នាទៅវិញទៅមក : ភាគីចុះកិច្ចសន្យាត្រូវតែខំប្រឹងខ្នះខ្នែង ក្នុងកិច្ចសហប្រតិបត្តិការអោយដល់ទីបំផុត និងជួយគ្នាទៅវិញទៅមក រវាងទីភ្នាក់ងារពាក់ព័ន្ធ ដែលមានជាប់ទាក់ទងក្នុងការសំរួល ដល់ការដឹកជញ្ជូនទំនិញ ឆ្លងកាត់ក្នុងអាស៊ាន ។

## ភាគទី ១

## បញ្ញត្តិទូទៅ

### មាត្រាទី ៣

### និយមន័យ

សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :

ក- " ការដឹកជញ្ជូនឆ្លងកាត់ " មានន័យថា ការឆ្លងកាត់ទំនិញ និងមានន័យថា ជាការដឹកជញ្ជូនឆ្លងកាត់ទឹកដី មួយ ឬ ច្រើននៃភាគីចុះកិច្ចសន្យា នៅពេលដែលការធ្វើដំណើរ កាត់តាមទឹកដីនៃប្រទេសមួយ ឬ ច្រើនដោយមាន ឬ មិនមានការផ្ទេរផ្ទុកទំនិញ ការដាក់បញ្ចូលឃ្លាំងផ្ទុកអីវ៉ាន់ ការបំបែកទំនិញជាដុំៗ ឬ ការផ្លាស់ប្តូរប្រភេទ នៃមធ្យោបាយដឹកជញ្ជូន គឺគ្រាន់តែជាចំណែកមួយ នៃការធ្វើដំណើរមួយពេញលេញ( មួយចប់ផ្លូវ ) ដែលការចាប់ផ្តើមនិងការបញ្ចប់ទៅហួសផុត ពីព្រំដែន នៃភាគីចុះកិច្ចសន្យាមួយ ឬ ច្រើនដែលចរាចរធ្វើដំណើរឆ្លងកាត់តាមទឹកដី ទាំងនោះ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

ខ-"ការដឹកជញ្ជូនក្នុងប្រទេស" មានន័យថាជាការដឹកនាំទំនិញទាំងឡាយ ដែលផ្ទុកនៅក្នុងទឹកដីនៃភាគីធ្វើកិច្ចសន្យាមួយ សំរាប់ការផ្ទេរដាក់ចុះទៅក្នុងកន្លែងមួយ នៅក្នុងទឹកដីនៃភាគីចុះកិច្ចសន្យាតែមួយដូចគ្នានោះ ។

គ-"មធ្យោបាយដឹកជញ្ជូន" មានន័យថា ជាយានយន្តផ្លូវគោកទាំងឡាយ មធ្យោបាយអូសទាញ និងដឹកជញ្ជូនរបស់ផ្លូវដែក នាវាសមុទ្រ និងកបាល់ដឹកជញ្ជូនលើផ្លូវទន្លេ ខាងក្នុងប្រទេស និងដឹកតាមយន្តហោះ ។

ឃ-"ទំនិញមានគ្រោះថ្នាក់" មានន័យថា ជារូបធាតុពិសេសៗ និងវត្ថុទាំងឡាយដែលអាចមានឥទ្ធិពលប៉ះពាល់ដល់ផលប្រយោជន៍ ខាងបរិស្ថាន សុខភាព សុវត្ថិភាព និងសន្តិសុខជាតិ ។

ង-"ទំនិញងាយខូចរលួយ" មានន័យថា ទំនិញស្រស់ ត្រីដែលគេធ្វើអោយត្រជាក់ ឬ បង្កក បង្កង សត្វទឹក-សត្វសមុទ្រមានសំបករឹងពីខាងក្រៅ សិប្បីសត្វ ផ្លែឈើ បន្លែ សាច់ដែលគេធ្វើអោយត្រជាក់ ឬ បង្កក បសុបក្សី ទឹកដោះ ផលិតផលធ្វើពីទឹកដោះ ស៊ុត និងផលិតផលធ្វើពីស៊ុត និងជ្រូក និងផលិតផលធ្វើពីសាច់ជ្រូក ។

ច-"អគ្គលេខាធិការ" មានន័យថា អគ្គលេខាធិការ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ។

## មាត្រាទី ៤

## វិសាលភាពនៃការអនុវត្តន៍

១- មាត្រាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ត្រូវតែអនុវត្តទៅលើការដឹកជញ្ជូនឆ្លងកាត់ ។

២- ការដឹកជញ្ជូនរវាងរដ្ឋ ត្រូវបានយល់ព្រមទៅវិញទៅមកដោយភាគីធ្វើកិច្ចសន្យា ។ សំរាប់គោលបំណងនេះ ភាគីចុះកិច្ចសន្យាត្រូវ ចូលទៅធ្វើការចរចារ និងសំរេចយ៉ាងរួសរាន់ នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីអំពីការសំរួល ការដឹកជញ្ជូនរវាងរដ្ឋ ។

## មាត្រាទី ៥

## ការផ្តល់សិទ្ធិ

១- យោងទៅតាមមាត្រាទាំងឡាយ ដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ភាគីចុះកិច្ចសន្យានិមួយៗ ត្រូវតែផ្តល់ទៅអោយភាគីចុះកិច្ចសន្យាដទៃទៀត :

ក- សិទ្ធិក្នុងការដឹកជញ្ជូនឆ្លងកាត់

ខ- សិទ្ធិក្នុងការផ្ទុក និងផ្ទេរ ទំនិញប្រទេសទី ៣ ដែលដឹកឆ្ពោះ ឬ ក៏ ដឹកមកពីភាគីចុះកិច្ចសន្យានានា

២- ភាគីធ្វើកិច្ចសន្យាទាំងឡាយ ដែលការដឹកជញ្ជូនឆ្លងកាត់ប្រព្រឹត្តទៅដោយកាត់តាមទឹកដី ឬ តាមតំបន់ របស់ខ្លួនណាមួយនោះ ត្រូវខិតខំប្រឹងប្រែងក្នុងការផ្តល់ តាមតែអាចធ្វើទៅបានដល់ការសម្រួលក្នុងការដឹកជញ្ជូនឆ្លងកាត់ដោយស្របទៅតាមមាត្រាដែលមានចែង ក្នុងកិច្ចព្រមព្រៀងនេះ ។

៣- ការដឹកជញ្ជូនឆ្លងកាត់មិនត្រូវបានគេដាក់អោយនៅក្រោមអំណាច ឬ ឥទ្ធិពល ក្នុងការពន្យាពេលណាមួយមិនចាំបាច់ ឬ ការដាក់កំហិត-លក្ខខ័ណ្ឌ និងត្រូវលើកលែងអោយរួចពន្ធគយ អាករ និងការបង់ថ្លៃផ្សេងទៀត លើកលែងតែការបង់ថ្លៃ ឬ ការហូតកំរៃសំរាប់សេវាជាក់លាក់ ដែលបានផ្តល់អោយក្នុងការតភ្ជាប់ជាមួយការដឹកជញ្ជូន ដូចខាងលើនេះ ។

៤- ទំនិញដែលដឹកនាំតាមរថយន្តលើផ្លូវគោកដែលមានតែមប្រិ ឬ ត្រាបិទភ្ជិត យានយន្តច្រើនប្រភេទបញ្ចូលគ្នា ឬ កុងតែន័រ មិនត្រូវដាក់អោយនៅក្រោមការត្រួតពិនិត្យ នៅឯប៉ុស្តិ៍គយនៅតាមផ្លូវគោកទាំងឡាយទេ។ ទោះបីជាយ៉ាងណាក៏ដោយ ដើម្បីបង្ការទុកជាមុននូវការរំលោភខ្លះៗ ដូចជាការរត់ពន្ធគយ និងការបន្លំអាជ្ញាធរគយទាំងឡាយ នៃភាគីចុះកិច្ចសន្យាណាមួយ អាចក្នុងករណីលើកលែង និងជាពិសេសនៅពេលដែលមានភាពមិនប្រក្រតី ដែលគួរអោយសង្ស័យ អាចអនុវត្តការត្រួតពិនិត្យទំនិញទាំងឡាយ នៅប៉ុស្តិ៍ទាំងនោះ ឬ កន្លែងដទៃទៀត ដែលបានកំនត់ដោយអាជ្ញាធរគយ ។

## ភាគទី ២
## ការរៀបចំសំរេចទុកជាមុននៃផ្លូវដឹកជញ្ជូនឆ្លងកាត់

### មាត្រាទី ៦
### ការរៀបចំសំរេចទុកជាមុន នៃផ្លូវដឹកជញ្ជូនឆ្លងកាត់ និងការសំរបសំរួល

១- ភាគីចុះកិច្ចសន្យាត្រូវតែយល់ព្រមធ្វើបញ្ជីមួយ នៃការកំណត់ផ្លូវដឹកជញ្ជូនឆ្លងកាត់ទុកជាមុន ដែលគេបានចែងយ៉ាង ជាក់លាក់ នៅក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀងនេះ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

២- សំរាប់ជាប្រយោជន៍ដល់សុវត្ថិភាព ភាគីចុះកិច្ចសន្យា ត្រូវតែខិតខំខ្នះខ្នែងផ្តល់អោយនៅក្នុងទឹកដីរបស់ខ្លួន ទីកន្លែងសំរាប់ឈប់សំរាក សំចតយានយន្តនៅលើផ្លូវដែលបានបញ្ជាក់ទាំងនេះ នៅក្នុងរយៈពេលមួយសមរម្យ ។

## មាត្រាទី ៧
## ការសំរួលនៅតាមព្រំដែន

១- ភាគីចុះកិច្ចសន្យាយល់ព្រមកំនត់ប៉ុស្តិតាមព្រំដែនទាំងឡាយ នៅឯចំនុចច្រកព្រំដែននានា ដែលត្រូវបានបញ្ជាក់ក្នុងពិធីសារទី ២ ដើម្បីសំរួលការដឹកជញ្ជូនឆ្លងកាត់ ។

២- ភាគីចុះកិច្ចសន្យា ត្រូវតែផ្តល់អោយនូវមធ្យោបាយសំរួលសមរម្យ និងការដាក់ទីតាំងពាក់ពន្ធ័ទាំងឡាយអោយបានគ្រប់គ្រាន់ នៅឯប៉ុស្តិតាមព្រំដែន នៅលើផ្លូវដឹកជញ្ជូនឆ្លងកាត់ ។

៣- ភាគីចុះកិច្ចសន្យាត្រូវតែខំប្រឹងប្រែងដើម្បី :

ក- ផ្តល់អោយនៅពេលណាមួយក៏ដោយ ដែលអាចធ្វើទៅបាន និងស្របទៅតាមយុត្តាធិការជាតិរបស់គេ ប៉ុស្តិនៅតាមព្រំដែនដែលស្ថិតនៅជាប់គ្នាជារូបវន្ត ទៅនឹងប៉ុស្តិព្រំដែនទាំងឡាយនៃភាគីចុះកិច្ចសន្យាដ៏ទៃដែលជាប់ពាក់ពន្ធ័ ដែលមានតំបន់ត្រួតពិនិត្យជាមួយនឹងតំរូវការអោយមានការរែករេរពិនិត្យដើម្បីសំរួលបែបបទ ឆ្លងដែន និងការត្រួតពិនិត្យ នូវមធ្យោបាយ ដឹកជញ្ជូន និងទំនិញ ឆ្លងកាត់ដើម្បី ចៀសវាង ការធ្វើឡើងវិញ នូវពេលដែលទំនិញត្រូវរើចេញ និងផ្ទុកចូល ។ ពុំមានអ្វីត្រូវបង្ការទុកជាមុន ពីភាគី ២ ឬ ភាគីច្រើននៃភាគីចុះកិច្ចសន្យា ក្នុងករណីបង្កើតឡើង នូវការត្រួតពិនិត្យរួមគ្នា នៅកន្លែងតែមួយដោយមន្ត្រីផ្លូវការ នៃភាគីធ្វើកិច្ចសន្យានោះទេ ។

ខ- ធានាថា ត្រូវមានធនធានមនុស្ស ធ្វើការងារគ្រប់គ្រាន់ សំរាប់បំពេញក្រដាសស្នាម និងបែបបទគយអោយបានរហ័សទៅតាមទំរង់បែបបទនៅតាមព្រំដែន ដូចជាការត្រួតពិនិត្យផ្នែកអន្តោប្រវេសន៍, គយ សុខាភិបាល និង ការប្តូររូបិយប័ណ្ណបរទេស ។

គ- អនុញ្ញាតអោយទំនិញឆ្លងកាត់ទាំងឡាយគរទុកក្នុងឃ្លាំងជាបណ្តោះអាសន្នក្នុងកន្លែងដែលបានឯកភាព

ឃ- សំរបសំរួលម៉ោងធ្វើការប៉ុស្តិដែលជិតគ្នា ។

ង- ផ្តល់អោយនៅទីណាក៏ដោយតាមតែអាចប្រព្រឹត្តទៅបានទីលានសំចតគ្រប់គ្រាន់សំរាប់កុងតែន័រ និងសំរាប់យានយន្ត ដែលរង់ចាំបំពេញបែបបទគយ ទំនិញ ។

៤- ភាគីជាប់កិច្ចសន្យានិមួយៗ ទោះនៅទីណាក៏ដោយ តាមដែលអាចធ្វើទៅបាន ត្រូវតែយកចិត្តទុកដាក់ពិចារណា ដល់មាត្រា ទាំងឡាយនៃអនុសញ្ញាសហប្រជាជាតិ ស្តីពីការសំរបសំរួលគ្នាលើការត្រួតពិនិត្យទំនិញនៅតាមព្រំដែន ដែលបាន ចុះហត្ថលេខា នៅទីក្រុង Geneva នៅថ្ងៃទី ២១ តុលា ឆ្នាំ ១៩៨២ ។

## ភាគទី ៣

## លក្ខខ័ណ្ឌនៅសំរាប់ការដឹកជញ្ជូនតាមផ្លូវគោក

### មាត្រាទី ៨

### បទប្បញ្ញត្តិចរាចរ

ភាគីចុះកិច្ចសន្យាត្រូវតែខំប្រឹងរិះរកវិធានការអោយបានសមរម្យ ដើម្បីធានាការចុះសំរុងគ្នាគ្នានូវបទបញ្ញត្តិ វិធាប់ចរាចរផ្លូវគោកដែលស្ថិតនៅជាធរមាននៅក្នុងដែនដីរបស់គេ ដែលអនុលោមទៅតាមខ្លឹមសារមាត្រាទាំងឡាយ ដែលមានចែងក្នុងអនុសញ្ញាស្តីពីចរាចរផ្លូវគោក ដែលចុះហត្ថលេខានៅទីក្រុង Vienna នៅថ្ងៃទី ០៨ វិច្ឆកា ឆ្នាំ ១៩៦៨ និង អនុសញ្ញាស្តីពីផ្លាកសញ្ញា និងភ្លើងសញ្ញាផ្លូវគោក ដែលបានចុះហត្ថលេខានៅទីក្រុង Vienna ក្នុងថ្ងៃទី ០៨ ខែ វិច្ឆកា ឆ្នាំ ១៩៦៨ ។

### មាត្រាទី ៩

### សេវាកម្មដឹកជញ្ជូនឆ្លងកាត់

១- ភាគីចុះកិច្ចសន្យានិមួយៗ ត្រូវតែអនុញ្ញាតអោយប្រើប្រាស់នូវមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលបានចុះបញ្ជីនៅភាគីចុះកិច្ចសន្យាដ៏ទៃផ្សេងទៀត ដើម្បីផ្តល់អោយនូវសេវាកម្មដឹកជញ្ជូនឆ្លងកាត់ នៅលើដែនដីរបស់គេ ដោយអនុលោមទៅតាមមាត្រា ៥ នៃកិច្ចព្រមព្រៀងនេះ ។

២- ប្រភេទនិងបរិមាណនៃយានយន្ត ផ្លូវគោកទាំងឡាយ ដែលត្រូវបានគេប្រើប្រាស់សំរាប់ការដឹកជញ្ជូនឆ្លងកាត់ ត្រូវតែបានគេយល់ព្រមជាមុន រវាងភាគីធ្វើកិច្ចសន្យាទាំងអស់ ដែលបានបញ្ជាក់នៅក្នុងពិធីសារទី ៣ នៅមុនពេលចាប់ផ្តើមបើកជាផ្លូវការ ការធ្វើសេវាកម្មដឹកជញ្ជូន ។ ជាបន្តបន្ទាប់ទៀតប្រភេទ និងបរិមាណ នៃយានយន្តផ្លូវគោក ត្រូវបានគេលើកយកមកពិភាក្សាពីពេលមួយ ទៅពេលមួយ រវាងភីចុះកិច្ចសន្យា ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ១០
## ការអនុញ្ញាតអោយធ្វើការដឹកជញ្ជូនតាមផ្លូវគោក

ភាគីធ្វើកិច្ចសន្យាត្រូវទទួលរ៉ាប់រងធ្វើអោយស៊ីសង្វាក់គ្នា ស្រុះស្រួលគ្នា នូវតម្រូវការទាំងឡាយក្នុងការអនុញ្ញាតអោយធ្វើការដឹកជញ្ជូនតាមផ្លូវគោក ដើម្បីសំរួលដល់ការដឹកជញ្ជូនឆ្លងកាត់ ។

## មាត្រាទី ១១
## តម្រូវការបច្ចេកទេសយានយន្ត

មធ្យោបាយដឹកជញ្ជូនទាំងឡាយដែលប្រើប្រាស់ ក្នុងការដឹកជញ្ជូនឆ្លងកាត់តាមផ្លូវគោក ត្រូវតែអនុលោមទៅតាមបច្ចេកទេសដែលតម្រូវអោយយោលទៅលើទំហំយានយន្ត ទំងន់យានយន្តនិងបន្ទុកទំនិញអតិបរិមា ស្តង់ដារនៃការបញ្ចេញផ្សែង និងបញ្ហាផ្សេងៗដែលពាក់ព័ន្ធ ដែលនឹងត្រូវបានគេបញ្ជាក់ នៅពិធីសារទី ៤ ។

## មាត្រាទី ១២
## ការទទួលស្គាល់ទៅវិញទៅមក នូវវិញ្ញាបនបត្រត្រួតពិនិត្យ

១- ភាគីចុះកិច្ចសន្យាទាំងឡាយត្រូវទទួលរ៉ាប់រង ដើម្បីចាត់តាំងឡើងនូវការត្រួតពិនិត្យជាតំណាក់កាល (ខួប) បណ្តាយានយន្តផ្លូវគោកទាំងឡាយ ដែលបានចុះបញ្ជីនៅក្នុងដែនដីរៀងៗខ្លួន និងដែលបានប្រើប្រាស់ សំរាប់ប្រតិបត្តិការនានា នៃការដឹកជញ្ជូនឆ្លងកាត់ ។

២- ភាគីចុះកិច្ចសន្យា ត្រូវតែទទួលស្គាល់វិញ្ញាបនប័ត្រត្រួតពិនិត្យជាតំណាក់កាលខួប នៃបណ្តាយានយន្តផ្លូវគោកដែលបានប្រើប្រាស់សំរាប់ការដឹកជញ្ជូនឆ្លងកាត់ ដែលចេញដោយភាគីធ្វើកិច្ចសន្យាដទៃទៀត ស្របទៅតាមកិច្ចព្រមព្រៀង ស្តីពីការទទួលស្គាល់វិញ្ញាបនប័ត្រត្រួតពិនិត្យយានយន្តពាណិជ្ជកម្ម សំរាប់រថយន្តដឹកទំនិញ និងរថយន្តបំរើសេវាសាធារណៈ ដែលចេញអោយដោយប្រទេសជាសមាជិកអាស៊ាន ដែលបានចុះហត្ថលេខានៅសិង្ហបុរី ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ ១៩៩៨ ។

## មាត្រាទី ១៣
## ការទទួលស្គាល់ទៅវិញទៅមក នូវប័ណ្ណបើកបរ

ភាគីចុះកិច្ចសន្យាត្រូវតែទទួលស្គាល់ប័ណ្ណបើកបរក្នុងប្រទេសដែលចេញដោយភាគីធ្វើកិច្ចសន្យា ដទៃទៀតទាំងអស់ ស្របទៅតាមកិច្ចព្រមព្រៀង ស្តីពីការទទួលស្គាល់អាជ្ញាប័ណ្ណបើកបរក្នុងប្រទេសដែលចេញដោយ បណ្តាប្រទេសអាស៊ានដែល បានចុះហត្ថលេខានៅ កូឡាឡាំពួរ កាលពីថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ១៩៨៥ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ១៤
## គ្រោងការធានារ៉ាប់រងរបស់ភាគីទី ៣ នៅលើយានយន្ត

១- យានយន្តផ្លូវគោកដែលចូលទៅក្នុងដែនដី នៃភាគីចុះកិច្ចសន្យាដទៃទៀត ត្រូវតែគោរពតាមយ៉ាងម៉ឺងម៉ាត់នូវច្បាប់និងបទប្បញ្ញត្តិទាំងឡាយ ដែលទាក់ទងទៅនឹងការធានារ៉ាប់រងរបស់ភាគីទី ៣ ពាក់ព័ន្ធទៅលើការធានាធានារ៉ាប់រងមធ្យោបាយ ដឹកជញ្ជូន របស់គេទាំងឡាយ ដើម្បីគ្របដណ្តប់ទៅលើការទទួលខុសត្រូវរបស់ភាគីទីបី ដែលជាទិសដៅ នៃការដឹកជញ្ជូនឆ្លងកាត់ ។

២- ភាគីចុះកិច្ចសន្យា ត្រូវទទួលរ៉ាប់រងធ្វើអោយស៊ីសង្វាក់គ្នា ស្រុះស្រួលគ្នា ឬ បង្កើតគ្រោងការអាស៊ានមួយជាទីពេញនិយម នៃការធានារ៉ាប់រងលើភាពទទួលខុសត្រូវរបស់ភាគីទី ៣ ទៅលើយានយន្តដែលមិនអាចខានបាន ហើយដែលត្រូវ បានបញ្ជាក់ ក្នុងពិធីសារទី ៥ ។

៣- គ្រោងការអាស៊ាន នៃការធានារ៉ាប់រង លើភាពទទួលខុសត្រូវ ដែលមិនអាចខានបានរបស់ភាគីទី ៣ ទៅលើយានយន្ត ត្រូវតែផ្តល់អោយយ៉ាងហោចណាស់ នូវការធានាទាំងអស់ ដែលបានតម្រូវដោយច្បាប់និងបទប្បញ្ញត្តិនានា ក្នុងការគ្រប់គ្រងនូវការធានារ៉ាប់រង ដែលមិនអាចខានបានរបស់ភាគីទីបី ទៅលើយានយន្តនៅក្នុងប្រទេសភាគីចុះកិច្ចសន្យាទាំងឡាយ ។

## មាត្រាទី ១៥
## ការបង់ថ្លៃ និងការតព្វកិច្ចហិរញ្ញវត្ថុដទៃទៀត

ភាគីចុះកិច្ចសន្យា ខំប្រឹងធ្វើអោយងាយស្រួល បង្រួបបង្រួម និងធ្វើអោយចុះសំរុងគ្នា ការបង់ថ្លៃ ( វិភាគទាន ) និងកាតព្វកិច្ចហិរញ្ញវត្ថុនានា ដែលគឺជាការហូតយកកំរៃទៅលើមធ្យោបាយដឹកជញ្ជូន ។

## ភាគីទី ៤
## <u>លក្ខខណ្ឌនៅសំរាប់ការដឹកជញ្ជូនតាមផ្លូវដែក</u>

## មាត្រាទី ១៦
## ការតភ្ជាប់ និងសេវាកម្មឆ្លងកាត់

១- ការតភ្ជាប់ និងសេវាកម្មឆ្លងកាត់ នៅលើផ្លូវអោយស្វ័យយាន ក្នុងការភ្ជាប់ដែនដី នៃបណ្តាភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវតែគេបង្កើតអោយមានសកម្មភាព នៅឯស្ថានីយកំណត់សំរាប់ការប្តូរ ឬបំបែកផ្លូវទៅវិញទៅមកទាំងឡាយ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

២- បណ្តាស្ថានីយតាមព្រំដែនទាំងឡាយ ស្ថានីយប្តូរ ឬបំបែកផ្លូវទាំងឡាយ ប្រភេទ និងបរិមាណ នៃមធ្យោបាយ (រទេះ ≈ ក្បាលរថភ្លើង - ទូ) និងត្រូវបានកំណត់ឡើង នៅក្នុងពិធីសារទី ៦ ។ ពិធីសារនេះក៏ត្រូវតែបញ្ជាក់ផងដែរ ការរៀបចំប្រតិបត្តិការជាមូលដ្ឋាននានា ដែលមានជាប់ទាក់ទងបញ្ហាខ្លះៗ ដូចជាបច្ចេកទេស ត្រួតពិនិត្យមធ្យោបាយ ( រទេះ ឬ រថ ក្បាលរថ+ទូ )

៣- ភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវតែជំរុញផ្លូវអោយស្ម័យយានរបស់គេ ដើម្បីបង្កើតឡើងនូវកិច្ចព្រមព្រៀងរវាងផ្លូវដែក (អន្តរផ្លូវដែក) ដោយរាប់បញ្ចូល ការរៀបចំសំរាប់ការទទួលស្គាល់ការត្រួតពិនិត្យខាងបច្ចេកទេស នៃមធ្យោបាយរថភ្លើង ដែលអនុលោមទៅតាមមាត្រាទាំងឡាយ ដែលមានចែង ក្នុងកិច្ចព្រមព្រៀងនេះ និងពិធីសាររបស់វា ។

## ភាគទី ៥

## វិធានការត្រួតពិនិត្យ គយ អនាម័យ និងភូតាមអនាម័យ

### មាត្រាទី ១៧

### ការធ្វើអោយចុះសំរុងគ្នា និងធ្វើអោយងាយស្រួលដល់និតិវិធីគយ

១- ភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវធ្វើអោយងាយស្រួល និងនៅពេលណាក៏ដោយតាមដែលអាចធ្វើទៅបាន ការធ្វើអោយស្រុះស្រួលគ្នានូវនិតិវិធីត្រួតពិនិត្យគយ ក្នុងការដឹកជញ្ជូនឆ្លងកាត់ ដើម្បីធានាអោយមានការប្រព្រឹត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិនានា ដែលគយគឺជាអ្នកទទួលខុសត្រូវក្នុងការប្រតិបត្តិច្បាប់ ( ការបង្ខំអោយគោរពច្បាប់ ) ។

២- ភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវសំរបសំរួលអោយមានការចូលរួមគ្នាក្នុងការត្រួតពិនិត្យផ្នែកគយ ទោះជានៅកន្លែងណាក៏ដោយតាមដែលអាចធ្វើទៅបាន នៃការដឹកជញ្ជូនឆ្លងកាត់ទៅចំណុចនានា ដែលបានកំណត់តាមព្រំដែនរបស់ពួកគេ ។

៣- ភាគីចុះកិច្ចសន្យាទាំងឡាយ យល់ព្រមធ្វើតាមការណែនាំ ទោះពេលណាក៏ដោយតាមដែលអាចធ្វើទៅបាន ទៅតាមស្តង់ដារ និងការណែនាំអនុវត្ត នូវឧបសម្ព័ន្ធ E1 ដែលពាក់ព័ន្ធដល់ផ្នែកគយក្នុងការឆ្លងកាត់ នៃអនុសញ្ញាអន្តរជាតិ ស្តីពីការសំរួល និងធ្វើអោយចុះសំរុងគ្នានូវនិតិវិធីគយ ដែលបានសំរេចឡើងនៅឯ KYOTO នៅថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ១៩៧៣ ដូចដែលបានធ្វើការកែប្រែ ក្រោមការឧបត្ថម្ភនៃអង្គការគយពិភពលោក ។

## មាត្រាទី ១៨

## ការបង្កើតនូវប្រព័ន្ធឆ្លងកាត់គយតែមួយ

១- ភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវតែបង្កើតនូវប្រព័ន្ធ ឆ្លងកាត់គយតែមួយ សំរាប់គោលបំណង នៃការសំរួលចលនាទំនិញនៅក្នុងដែនដីរបស់គេ ។

២- ភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវតែយល់ព្រមក្នុងការអនុវត្តន៍ប្រព័ន្ធគយសំរាប់ការឆ្លងកាត់ ដែលនឹងត្រូវបានបញ្ជាក់នៅក្នុងពិធីសារទី ៧ ។

## មាត្រាទី ១៩

## ការបង្កើតវិធានការអនាម័យ និងភូតាមអនាម័យ

ភាគីចុះកិច្ចសន្យាទាំងឡាយ ត្រូវបង្កើតវិធានការអនាម័យ និងភូតាមអនាម័យ ដែលនឹងត្រូវបញ្ជាក់នៅក្នុងពិធីសារទី ៨ ដើម្បីសំរួលចលនាទំនិញនៅក្នុងដែនដីរបស់គេ និងធានាអោយមានការប្រព្រឹត្តទៅតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលអាជ្ញាធរពាក់ព័ន្ធ ជាអ្នកទទួលខុសត្រូវសំរាប់ការបង្ខំអោយអនុវត្តច្បាប់ ។

## ភាគទី ៦

## <u>មាត្រាផ្សេងៗ</u>

## មាត្រាទី ២០

## មាត្រាពិសេស ស្តីពីការដឹកជញ្ជូនទំនិញមានគ្រោះថ្នាក់

ការដឹកជញ្ជូនឆ្លងកាត់ នូវទំនិញដែលអាចនាំអោយមានគ្រោះថ្នាក់ នឹងត្រូវបានបញ្ជាក់នៅក្នុងពិធីសារទី ៩ នឹងមិនត្រូវបានអនុញ្ញាតអោយស្ថិតនៅក្រោមកិច្ចព្រមព្រៀងនេះទេ ដរាបណាមានការអនុញ្ញាតពិសេសនៃភាគីចុះកិច្ចសន្យាណាមួយនៅក្នុង ដែនដីរបស់គេ ដែលការដឹកជញ្ជូននោះ ត្រូវបានគេទទួលរ៉ាប់រងខុសត្រូវ ។

01/09/99 Protocaol-3
ពង្រាងបញ្ចប់លើកទី ១

## មាត្រាទី ២១
## មាត្រាពិសេស ស្តីពីការដឹកជញ្ជូនទំនិញហាមឃាត់ និង/ឬ ទំនិញជាប់កំហិត

ការដឹកជញ្ជូនឆ្លងកាត់នូវទំនិញហាមឃាត់ ឬ ទំនិញជាប់កំហិត ក្នុងការឆ្លងកាត់ដែនដី នៃភាគីចុះកិច្ចសន្យាមួយ ដែលគេបានបញ្ជាក់ក្នុងពិធីសារទី ៧ នឹងមិនត្រូវបានគេអនុញ្ញាត អោយនៅក្រោមកិច្ចព្រមព្រៀងនេះទេ ។

## មាត្រាទី ២២
## មាត្រាពិសេស ស្តីពីការដឹកជញ្ជូនទំនិញដែលងាយខូចខាត

យោងតាមមាត្រាទាំងឡាយ នៅក្នុងកិច្ចព្រមព្រៀងនេះ ភាគីចុះកិច្ចសន្យាទាំងអស់ ត្រូវតែខំប្រឹងសំរួល ដល់ការដឹកជញ្ជូនទំនិញដែលងាយខូចខាត ។

## មាត្រាទី ២៣
## មាត្រានៃការសំរួលទូលំទូលាយ

កិច្ចព្រមព្រៀងនេះមិនតម្រូវអោយធ្វើតាមវិធីណាមួយ ក្នុងការដកចេញនូវការសំរួលការឆ្លងកាត់ ដែលទូលំទូលាយជាងការសំរួលទាំងនោះ ដែលបានចែងក្នុងកិច្ចព្រមព្រៀងនេះ ដែលមានអាយុកាលវែង ដូចគ្នាទៅនឹងចំណែក និង ល័ក្ខខណ្ឌទាំងឡាយ ដែលមាននិរន្តរភាព ទៅតាមគោលការណ៍ទាំងឡាយ ដែលលេចជារូបរាងឡើង ក្នុងកិច្ចព្រមព្រៀងនេះ ។ កិច្ចព្រមពៀងនេះ ក៏មិនតម្រូវអោយប្រានចោលជាមុន ការផ្តល់អោយនូវការសំរួលទូលំទូលាយទាំងឡាយ ដែលអាចយល់ព្រមឡើងរវាងភាគីចុះកិច្ចសន្យាទាំងឡាយ ក្នុងពេលអនាគត ។

## មាត្រាទី ២៤
## ច្បាប់ក្នុងប្រទេស

១- ច្បាប់ និងបទប្បញ្ញត្តិខាងក្នុងប្រទេសទាំងឡាយ ដែលទាក់ទងទៅនឹងការដឹកជញ្ជូនទំនិញ ដ៏រាបណាកិច្ចព្រមព្រៀងនេះ និងពិធីសារនានារបស់វាទាំងឡាយ មិនត្រូវបានគេបោះបង់ចោល ត្រូវអនុវត្តដោយស្មើភាពគ្នា និងដោយគ្មានការរើសអើងទៅលើការដឹកជញ្ជូនឆ្លងកាត់ ។

២- ភាគីចុះកិច្ចសន្យាត្រូវខំប្រឹងប្រែង ធ្វើអោយចុះសំរុងគ្នា និងធ្វើអោយងាយស្រួលនូវវិធាន បទប្បញ្ញត្តិ និងនិតិវិធីរដ្ឋបាលទាំងឡាយ ដែលជាប់ទាក់ទងទៅនឹងការដឹកជញ្ជូនឆ្លងកាត់ ស្របទៅតាមមាត្រាដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។

## មាត្រាទី ២៥
